អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងផ្ត្រយោងប៉ោងប៉ោង**

**ចិត្តចលភាព** ៖ បំណិនចលករធំ៖ ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ។

៖ បំណិនចលករតូច៖ (ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក)។

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់និងយល់លេខតាងនិងការគណនាលេខសាមញ្ញៗ។

**សិក្សាសង្គម** ៖ បំណិនទំនាក់ទំនង៖ បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងជាមួយមិត្តភក្តិដែលមានវ័យប្រហាក់ប្រហែលគ្នា។

**គោលបំណង**

**ចិត្តចលភាព** ៖ **វិជ្ជាសម្បទា៖** ប្រាប់បានពីរបៀបធ្វើចលនាដៃ និងដងខ្លួនក្នុងការលើក បោះ ឬទប់ផ្ត្រយោងប៉ោងប៉ោងតាមការណែនាំ ។

**បំណិនសម្បទា៖**

- ប្រើប្រាស់ចលករតូច និងចលករធំ ក្នុងការទប់ លោត និងសម្របសម្រួល ចលនាដៃ ភ្នែក ពេលលេងល្បែង។
- កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹង និងការប្រកួតប្រជែង លេងជាក្រុមបានរឹងមាំល្អ។

**បុរេគណិត** ៖ **វិជ្ជាសម្បទា៖**

- ប្រាប់បានពីចំនួន លេខនិងយល់ន័យពី ១ដល់៣០ តាមលំដាប់លំដោយ ឬលើសពីនេះ។

**បំណិនសម្បទា៖**

- ប្រៀបធៀបចំនួនស្មើគ្នា តិចជាង ឬច្រើនជាងក្នុងចំនួន១ដល់១៥ ឬលើសពីនេះ នៃសម្ភារល្បែង ។
- រាប់ចំនួនកុមារ បាល់ ឬប៉ោងប៉ោង ក្នុងពេលកំពុងលេងល្បែង។

**សិក្សាសង្គម** ៖ **វិជ្ជាសម្បទា៖** ប្រាប់បានពីរបៀបលេងល្បែងសេរីដែលបានលេងជាបុគ្គលឬជាក្រុម។

**បំណិនសម្បទា៖** សហការ និងធ្វើការទំនាក់ទំនងល្អ ជាមួយមិត្តភក្តិក្នុងពេលលើក និង ទម្លាក់ឆ័ត្រយោងបានល្អ និងព្រមគ្នា។

**ចរិយាសម្បទា៖** បង្ហាញនូវស្មារតីសាមគ្គីភាព ការចែករំលែក និងការយោគយល់គ្នាក្នុងពេលលេងល្បែងជាមួយមិត្តភក្តិ។

**កម្រិតសិក្សា** ៖ មធ្យម និងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ប៉ោងៗ ឬបាល់ដែលស្រាលៗ ថង់ ឬក្រណាត់ដែលមានទំហំល្មមក្នុងការលេងល្បែងនេះ។

**ការរៀបចំ** ៖ ត្រៀមសម្ភារឱ្យបានគ្រប់គ្រងជ្រោយសម្រាប់លេងក្នុងល្បែងសកម្មភាពនេះ។

**សេចក្តីណែនាំ** ៖

1. សួរកុមារថាកូនៗស្គាល់ឆ័ត្រយោងអត់? ដែលឃើញអត់?
2. ប្រាប់កុមារទាំងអស់ថា ថ្ងៃនេះយើងនឹងទៅលេងល្បែងសកម្មភាពដែលសប្បាយមួយ ទាក់ទងនឹងឆ័ត្រយោង
3. ប្រាប់កុមារពីរបៀបលេងល្បែងនិងសារៈសំខាន់ក្នុងការលេងល្បែងសកម្មភាពមួយនេះ។
    - ❖ កុមារ៣ឬ៤នាក់កាន់តាមជ្រុងថង់ ឬក្រណាត់



- ដាក់ប៉ោងៗឬបាល់នៅលើថង់ ឬក្រណាត់
  បន្ទាប់មកចាប់ផ្តើមលេងដោយធ្វើឱ្យប៉ោងៗឬបាល់លោតលើក្រណាត់ដោយកុំឱ្យធ្លាក់




- ឱ្យកុមារលេងបែបនេះរហូតគ្រប់គ្នា និងទៅតាមពេលវេលាដែលគ្រូមានជាការស្រេច។

